# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៧៨

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានចាប់ផ្តើមបន្តសវនាការឡើងវិញ បន្ទាប់ពីបានឈប់សម្រាកអស់រយៈពេលពីរសប្តាហ៍ក្នុងអំឡុងពេលនៃការចូលឆ្នាំសកល ដោយបានរៀបចំសវនាការស្តាប់ការបង្ហាញឯកសារគន្លឹះស្តីពីតួនាទីរបស់ជនជាប់ចោទ។[1] មានតែក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទលោក **ខៀវ**

---

[1] សវនាការលើឯកសារគន្លឹះ ត្រូវបានរៀបចំឡើងនៅចុងបញ្ចប់នៃផ្នែកជំនុំជម្រះនីមួយៗ។ សវនាការលើឯកសារគន្លឹះ អនុញ្ញាតឲ្យភាគីទាំងអស់ធ្វើការដាក់បង្ហាញដល់ភាគីទៅវិញទៅមក នូវឯកសារគន្លឹះនានា ដែលមានភាពពាក់ព័ន្ធនឹងផ្នែកជំនុំជម្រះនីមួយៗ។ សូមមើលឯកសាររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី "ព័ត៌មានទី១ ស្តីពីសវនាការលើការដាក់បង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង០០២ វគ្គ២ និងព័ត៌មានទី២ ស្តីពីសវនាការស្តាប់ពីព្យសនកម្មរងទុក្ខវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ វគ្គ២" (ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤) ឯកសារលេខ E315/1។ សម្រាប់សេចក្តីសង្ខេបស្តីពីសវនាការលើឯកសារគន្លឹះលើកទី១ ក្នុងសំណុំរឿង០០២ វគ្គ២ ស្តីពីសហករណ៍ស្រុកត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ សូមមើលរបាយការណ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ១៧ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី១៤ (ចុះថ្ងៃទី២៧ ដល់៣០ ខែមេសា ឆ្នាំ២០១៥)។ សវនាការលើឯកសារគន្លឹះបន្ទាប់ ត្រូវបានរៀបចំនៅចុងបញ្ចប់នៃផ្នែកជំនុំជម្រះស្តីពីការរដ្ឋានការងារទាំងបី សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ២៨ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី២៥ (ចុះថ្ងៃទី២៤ ដល់ទី២៧ ខែសីហា ឆ្នាំ២០១៥) និងលេខ២៩ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី២៦ (ចុះថ្ងៃទី១ ដល់ទី៣ ខែកញ្ញា ឆ្នាំ២០១៥)។ សវនាការលើឯកសារគន្លឹះលើកទីបី បានផ្តោតលើការប្រព្រឹត្តទៅលើក្រុមគោលដៅ សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ៤៤ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៤១ (ចុះថ្ងៃទី២៣ ដល់ទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦) ទំព័រ ១ដល់៤។ សវនាការលើឯកសារគន្លឹះលើកទីបួន បានផ្តោតលើមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ៦២ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៥៩ (ចុះថ្ងៃទី១១ ដល់ទី១២ ខែសីហា ឆ្នាំ២០១៦) ទំព័រ៥ដល់៧ និងរបាយការណ៍លេខ៦៣ ស្តីពីសវនាការលើ

**សំផន** បានសម្រេចចិត្តធ្វើការបង្ហាញឯកសារគន្លឹះក្នុងសប្តាហ៍នេះ ហើយត្រូវបានផ្តល់ពេលវេលាចំនួនពីរវគ្គសវនាការផងដែរ ដើម្បីធ្វើបទបង្ហាញរបស់ខ្លួននៅពេលព្រឹកថ្ងៃពុធ។[2] នៅពេលរសៀលថ្ងៃព្រហស្បតិ៍ ការិយា-ល័យសហព្រះរាជអាជ្ញា ត្រូវបានផ្តល់ពេលវេលាចំនួនមួយវគ្គសវនាការ ដើម្បីឆ្លើយតបទៅនឹងឯកសារគន្លឹះដែលបានបង្ហាញដោយសហមេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទលោក **ខៀវ សំផន**។ ក្នុងអំឡុងពេលនៃការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិបានសម្អាងយោងលើឯកសារនានា ដែលមិនបានប្រើប្រាស់ក្នុងបទបង្ហាញខាងដើមរបស់ក្រុមការពារក្តីឲ្យលោក **ខៀវ សំផន** ដែលជាហេតុនាំឲ្យមានប្រតិកម្មជំទាស់ជាច្រើនលើកច្រើនសាពីសំណាក់ក្រុមមេធាវីការពារក្តី។ អង្គជំនុំជម្រះ បានសម្រេចអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាបន្តធ្វើបែបនេះ និងបានផ្តល់ឱកាសឲ្យក្រុមមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** ធ្វើការឆ្លើយតបទៅវិញនៅសប្តាហ៍ក្រោយនេះ។

---

ភស្តុតាង សប្តាហ៍ទី៦០ (ចុះថ្ងៃទី១៥ ដល់១៨ ខែសីហា ឆ្នាំ២០១៦) ទំព័រ៤។ សវនាការលើឯកសារគន្លឹះលើកទីប្រាំ បានផ្តោតលើការដាក់បទប្បញ្ញត្តិនៃការរៀបអាពាហ៍ពិពាហ៍ សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ៦៦ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៦៣ (ចុះថ្ងៃទី៥ ដល់ទី៨ ខែកញ្ញា ឆ្នាំ២០១៦) ទំព័រ ១ដល់៤។ សវនាការលើឯកសារគន្លឹះនាពេលថ្មីៗកន្លងទៅនេះ បានផ្តោតលើលក្ខណៈនៃជម្លោះប្រដាប់អាវុធ ក្នុងរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ៧២ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៦៩ (ចុះថ្ងៃទី៣១ ខែតុលា ដល់ទី៣ ខែវិច្ឆិកា ឆ្នាំ២០១៦) ទំព័រ ៥ដល់៨។

[2] ក្រុមមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** មិនតែងតែធ្វើបទបង្ហាញឯកសារគន្លឹះក្នុងសវនាការនេះជាញឹកញាប់នោះទេ។ ក្នុងសវនាការលើឯកសារគន្លឹះលើកទីពីរ និងលើកទីបួន ពួកគេបានធ្វើការឆ្លើយតបទៅនឹងឯកសារគន្លឹះនានាដែលបានបង្ហាញដោយសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏ប៉ុន្តែមិនបានចូលរួមធ្វើការបង្ហាញឯកសារនានារបស់ពួកគេឡើយ។ នេះគឺជាលើកទីមួយដែលសហព្រះរាជអាជ្ញា ជ្រើសរើសមិនធ្វើបទបង្ហាញឯកសារគន្លឹះរបស់ខ្លួនផងដែរ។ សម្រាប់សេចក្តីសង្ខេបនៃសវនាការលើឯកសារគន្លឹះ សូមមើលជើងទំព័រលេខ១ខាងលើ។

[*] របាយការណ៍នេះ ត្រូវបានសរសេរដោយ អាលីស៊ុន ហេនឌ្រិក (Allison Hendriks), អាមេនដា ហុញ (Amanda Huynh), ខេតលីន កាហ្វហ្រៀ (Caitlin McCaffrie), តាយ លីណា និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។